# សេចក្តីណែនាំអំពីរបៀបប្រើប្រាស់ប្រព័ន្ធទូរសព្ទ

# Android ភាសាខ្មែរ

សម្រាប់កំណែ Android 4.4+

# មាតិកា


១ អំពីសៀវភៅនេះ ............ ៣

២ សេចក្តីផ្តើម ............ ៤

៣ ទិដ្ឋភាពអេក្រង់ដំបូង ............ ៥

    ៣.១ ប៊ូតុងនាំទិសរបស់ ណអឹា ៥ ............ ៦

    ៣.២ ការរៀបចំអេក្រង់ដំបូង ............ ៨

        ៣.២.១ ផ្លាស់ប្តូរផ្ទាំងរូបភាពខាងក្រោយ ............ ៨

        ៣.២.២ បន្ថែមរូបតំណាងណាមួយទៅលើអេក្រង់ដំបូង ............ ៩

        ៣.២.៣ បន្ថែមជាតុក្រាហ្វិកទៅលើអេក្រង់ដំបូង ............ ៩

៤ គ្រួសៗអំពីការកំណត់ប្រព័ន្ធ ............ ១០

    ៤.១ ការប្តូរភាសានិងការបន្ថែមក្តារចុចខ្មែរ ............ ១០

    ៤.២ ការតភ្ជាប់បណ្តាញទិន្នន័យចល័តនិងវ៉ាយហ្វាយ ............ ១៦

    ៤.៣ កំណត់ការបង្ហាញ សំឡេង និងពេលវេលា ............ ១៨

        ៤.៣.១ កំណត់ការបង្ហាញ ............ ១៩

        ៤.៣.២ កំណត់សំឡេង ............ ១៩

        ៤.៣.៣ កំណត់ពេលវេលា ............ ២០

៥ កម្មវិធីទំនាក់ទំនង ............ ២១

    ៥.១ បន្ថែមទំនាក់ទំនងក្នុង កព្យអឡិញ្ឝិអ ............ ២១

        ៥.១.១ បន្ថែមផ្ទាល់ពីកន្លែងវាយលេខទូរសព្ទ ............ ២១

    ៥.២ ការផ្ញើសារខ្លីៗ ឬអ៊ីមែល ............ ២៣

        ៥.២.១ បើកការផ្ញើសារខ្លីៗនៅក្នុង ជហ្យញ្ញា ឳ ............ ២៣

៦ ការដំឡើង និងលុបកម្មវិធីបន្ថែម ............ ២៥

    ៦.១ រកមើលនិងដំឡើងកម្មវិធី ............ ២៥

    ៦.២ ការលុបកម្មវិធី និងការធ្វើបច្ចុប្បន្នភាពកម្មវិធី ............ ២៧

៧ កម្មវិធីបណ្តាញសង្គម និង ផព្យឈ ............ ២៩

# ១ អំពីសៀវភៅនេះ

សៀវភៅណែនាំនេះ នឹងបង្ហាញអំពីមូលដ្ឋានគ្រឹះនៃរបៀបប្រើប្រាស់ប្រព័ន្ធប្រតិបត្តិការ Android មានចំណុចប្រទាក់ជាភាសាខ្មែរ ដែលក្នុងនេះមានរួមបញ្ចូលចំណុចសំខាន់ៗដូចជារបៀបតភ្ជាប់អ៊ីនធឺណិត ការតភ្ជាប់វ៉ាយហ្វាយ ការរក្សាទុកឈ្មោះទំនាក់ទំនង ការហៅទូរសព្ទ បណ្ដាញសង្គម និងបណ្ដាញ VoIP នានា។ (មើលបញ្ជីមាតិកា។)

## តើសៀវភៅនេះសម្រាប់អ្នកណា?

សៀវភៅនេះត្រូវបានរៀបចំឡើងសម្រាប់អ្នកប្រើប្រាស់ទូរសព្ទ Android ដំបូង (កំណែ 4.4 ឡើងទៅ) ដែលមានជាភាសាខ្មែរស្រាប់ ឬក៏អ្នកដែលចេះប្រើប្រាស់ Android មួយចំនួនហើយ តែចង់ដឹងបន្ថែម។

# ២ សេចក្ដីផ្ដើម

នៅក្នុងអំឡុងខែតុលា ឆ្នាំ២០១៣ ក្រុមហ៊ុន Google បានបញ្ចេញកំណែថ្មីនៃប្រព័ន្ធប្រតិបត្តិការទូរសព្ទទំនើបរបស់ខ្លួន គឺ Android កំណែ 4.4 ។ នៅក្នុងកំណែនោះទៀតសោត ភាសាខ្មែរ និងអក្សរខ្មែរត្រូវបានបញ្ចូលឲ្យមានស្រាប់មកស្រាប់តែម្ដង។ ដូច្នេះហើយ ការដំឡើងភាសាខ្មែរ និងក្ដារចុចភាសាខ្មែរលែងជាការលំបាកសម្រាប់អ្នកប្រើទូរសព្ទ Android ទូទៅទៀតហើយ។ នៅចុងខែមិថុនា Google បានបន្តធ្វើបច្ចុប្បន្នភាពប្រព័ន្ធប្រតិបត្តិការមួយនេះឡើងដល់ 4.4.4 ។

# ៣ ទិដ្ឋភាពអេក្រង់ដំបូង

នៅផ្នែកខាងក្រោមនៃអេក្រង់ដំបូង (Home screen) អ្នកនឹងឃើញរបាររូបតំណាងកម្មវិធីសំខាន់ៗមួយជួរ ដែលជាកន្លែងឲ្យអ្នកអាចចូលទៅកម្មវិធីនានាបានរហ័ស។ ខាងក្រោមនេះជាទិដ្ឋភាពនៅលើ Google Nexus 7 ។



ប៉ះនៅលើរូបតំណាងនិមួយៗ ដើម្បីចូលទៅកាន់កម្មវិធីទាំងនោះ។

## ៣.១ ប៊ូតុងនាំទិសរបស់ Nexus

នៅផ្នែកក្រោមនៃអេក្រង់របស់ Nexus អ្នកនឹងឃើញមានប៊ូតុងនាំទិសចំនួនបី។ នៅលើទូរសព្ទអេនដ្រយប្រភេទផ្សេងៗមានរបារនាំទិសផ្សេងៗគ្នា។



**បកក្រោយ**

បើកត្រឡប់ទៅកាន់កម្មវិធីឬទីកន្លែងមុនៗដែលអ្នកបានស្ថិតនៅ។ អ្នកអាចចុចប៊ូតុងនេះរហូតដល់អេក្រង់ដំបូង (Home screen) វិញ។



**អេក្រង់ដំបូង**

ចុចប៊ូតុងនេះ ដើម្បីត្រឡប់ទៅកាន់អេក្រង់ដំបូងវិញបានភ្លាមមួយរំពេច។ បើចុចឲ្យជាប់ហើយអូសឡើងលើ គឺដើម្បីបើក Google Now ។



**កម្មវិធីថ្មីៗ**

បើកបញ្ជីកម្មវិធីដែលអ្នកបានបើកថ្មីៗ។ ប៉ះលើរូបតូចនៃកម្មវិធីទាំងនោះដើម្បីបើក ហើយអូសគ្រវាសទៅស្តាំឬឆ្វេងដើម្បីដកចេញពីបញ្ជី។

# ៣.២ ការរៀបចំអេក្រង់ដំបូង

អ្នកអាចរៀបចំអេក្រង់ដំបូងរបស់អ្នកទៅតាមចំណង់ចំណូលចិត្ត ដូចជាការដាក់ផ្ទាំងរូបភាពខាងក្រោយ, ធាតុក្រាហ្វិក (widget), រៀបចំរូបតំណាងនានាជាដើម។

## ៣.២.១ ផ្លាស់ប្តូរផ្ទាំងរូបភាពខាងក្រោយ

១. ប៉ះនិងសង្កត់ត្រង់កន្លែងទំនេរនៅលើអេក្រង់ដំបូង ។
២. ប៉ះលើពាក្យ «ផ្ទាំងរូបភាព» ។
៣. ជ្រើសយករូបភាពណាមួយដែលអ្នកពេញចិត្ត ដើម្បីផ្លាស់ប្តូរ ។






### ៣.២.២ បន្ថែមរូបតំណាងណាមួយទៅលើអេក្រង់ដំបូង

១. ទៅកាន់អេក្រង់ដំបូងណាមួយដែលអ្នកចង់ដាក់រូបតំណាងបន្ថែម។

២. ប៉ះនៅលើរូបតំណាង  «កម្មវិធីទាំងអស់» ។

៣. រកមើលកម្មវិធីដែលអ្នកចង់យកទៅដាក់នៅក្នុងអេក្រង់ដំបូង។

៤. ប៉ះនិងសង្កត់វារហូតដល់អេក្រង់ដំបូងបង្ហាញមក ហើយអូសយកទៅដាក់ត្រង់ណាដែលអ្នកចង់បាន រួចលែងម្រាមដៃចេញ។

### ៣.២.៣ បន្ថែមធាតុក្រាហ្វិកទៅលើអេក្រង់ដំបូង

១. ប៉ះនិងសង្កត់ត្រង់កន្លែងទំនេរនៅលើអេក្រង់ដំបូង។

២. ប៉ះលើពាក្យ «ធាតុក្រាហ្វិក» ។

៣. ជ្រើសយកធាតុក្រាហ្វិកណាមួយ ដោយប៉ះនិងសង្កត់វារហូតដល់អេក្រង់ដំបូងបង្ហាញមក ហើយអូសយកទៅដាក់ត្រង់ណាដែលអ្នកចង់បាន រួចលែងម្រាមដៃចេញ។

ដើម្បីបង្កើតថត អ្នកគ្រាន់តែទាញអូសរូបតំណាងណាមួយទៅដាក់ពីលើរូបតំណាងមួយអ្នក។

# ៤ ត្រួសៗ អំពីការកំណត់ប្រព័ន្ធ

ក្រៅពីការ  កំណត់លំនាំដើមនៅក្នុង Android អ្នកក៏អាចរៀបចំនិងកំណត់ប្រព័ន្ធរបស់អ្នកទៅតាមចំណូលចិត្តបានដែរ មានដូចជា៖

១. វ៉ាយហ្វាយ
២. ប្ល៊ូធូស
៣. ទិន្នន័យចល័ត
៤. អេក្រង់ដំបូង
៥. សំឡេង
៦. ការបង្ហាញ
៧. ការផ្ទុក
៨. ថ្ម (ថាមពល)
៩. កម្មវិធី
១០. ទីតាំង (GPS)
១១. សុវត្ថិភាព
១២. ភាសា & ការបញ្ចូល
១៣. កាលបរិច្ឆេទ និង ពេលវេលា
១៤. ភាពងាយស្រួល
១៥. ការបោះពុម្ព
១៦. អំពីទូរសព្ទ

## ៤.១ ការប្តូរភាសានិងការបន្ថែមក្តារចុចខ្មែរ

អ្វីដែលគួរឲ្យចាប់អារម្មណ៍នៅក្នុងប្រព័ន្ធប្រតិបត្តិការ Android កំណែ 4.4+ នោះគឺភាសានិងអក្សរខ្មែរត្រូវបានដាក់បញ្ចូលទៅក្នុងនោះជាស្រេច។ វានឹងផ្តល់សារប្រយោជន៍កាន់តែច្រើនសម្រាប់អ្នកប្រើជាជនជាតិខ្មែរក្នុងទំនាក់ទំនង។

អ្នកអាចផ្លាស់ប្ដូរភាសានិងបន្ថែមក្ដារចុចខ្មែរតាមវិធីខាងក្រោម៖

Ď. ចុចលើរូបតំណាងកម្មវិធីទាំងអស់ ហើយប៉ះលើ «**Settings**» ។

ď. រំកិលចុះក្រោម រកមើល «**Language & input**» បន្ទាប់មក «**Language**» ។

៣. រកមើលភាសា «ខ្មែរ» ហើយប៉ះលើវា។ វាអាចចំណាយពេលប៉ុន្មានវិនាទី ដើម្បីកែសម្រួលប្រព័ន្ធទាំងមូលឲ្យទៅជាភាសាខ្មែរទាំងស្រុង។




រូបភាព 1: ជ្រើសរើសភាសាខ្មែរ

ម្យ៉ាងវិញទៀត អ្នកក៏អាចបន្ថែមក្តារចុចខ្មែរបានផងដែរ ដែលមានស្រាប់នៅក្នុង «ក្តារចុច Google» ។ សូមចូលទៅកាន់ទីតាំង «**ភាសា & ការបញ្ចូល**» & «**Language & input**» ដដែល។

1. នៅត្រង់ផ្នែក **ក្តារចុច & វិធីសាស្ត្របញ្ចូល** , ប៉ះលើរូបការកំណត់ ដែលស្ថិតនៅខាងស្តាំ «ក្តារចុច Google» ។
2. ប៉ះលើ «បញ្ចូលភាសា» ហើយរកមើល **ខ្មែរ (កម្ពុជា)** រួចធីកយក។




រូបភាព 2: ជ្រើសយកក្តារចុច ខ្មែរ (កម្ពុជា)




រូបភាព 3: ទិដ្ឋភាពក្តារចុចខ្មែរ

## ៤.២ ការតភ្ជាប់បណ្ដាញទិន្នន័យចល័តនិងវ៉ាយហ្វាយ

អ្នកអាចតភ្ជាប់បណ្ដាញទិន្នន័យចល័ត 2G, 3G, 4G បាននៅក្នុងការកំណត់របស់ Android ។

1. ចូលទៅកាន់ «ការកំណត់» ដែលមាននៅក្នុងបញ្ជីកម្មវិធីទាំងអស់។
2. ប៉ះលើ «ច្រើនទៀត...» ដែលស្ថិតនៅក្នុងផ្នែក **បណ្ដាញ & ឥតខ្សែ**
3. ប៉ះលើ «បណ្ដាញចល័ត» ហើយចូលទៅកំណត់ **ឈ្មោះចំណុចចូលដំណើរការ** ឬ Access Points Name ដើម្បីកំណត់ព័ត៌មាននៃការតភ្ជាប់បណ្ដាញទិន្នន័យចល័ត។
4. ប៉ះលើសញ្ញា + ដែលស្ថិតនៅរបារខាងលើ ដើម្បីបន្ថែមឈ្មោះ។




5. បន្ទាប់ពីកំណត់ឈ្មោះនិងព័ត៌មានរួចហើយ ប៉ះលើប៊ូតុងម៉ឺនុយដែលស្ថិតនៅជ្រុងស្ដាំខាងលើ ដើម្បីរក្សាទុក ឬ បោះបង់ ឬ លុប។




6. ប៉ះរង្វង់មូលដែលស្ថិតនៅខាងស្ដាំឈ្មោះចំណុចណាមួយ ដើម្បីដាក់ជាការតភ្ជាប់លំនាំដើម។




អ្នកអាចតភ្ជាប់បណ្ដាញវ៉ាយហ្វាយបានដោយចូលទៅ ការកំណត់ ហើយប៉ះលើពាក្យ «វ៉ាយហ្វាយ» ។ អ្នកនឹងទទួលបានបញ្ជីវ៉ាយហ្វាយនានា។ ប៉ះលើឈ្មោះបណ្ដាញណាមួយ ដើម្បីតភ្ជាប់។




## ៤.៣ កំណត់ការបង្ហាញ សំឡេង និងពេលវេលា

អ្នកអាចកែតម្រូវការបង្ហាញ សំឡេង និងពេលវេលានៅក្នុងទូរសព្ទ Android របស់អ្នកបាន នៅក្នុង «ការកំណត់» ។

## ៨.៣.១ កំណត់ការបង្ហាញ

នៅក្នុងការកំណត់ រកមើលពាក្យ **បង្ហាញ** បន្ទាប់មកអ្នកនឹងទទួលបានផ្ទាំងកំណត់ការបង្ហាញ ដែលក្នុងនោះអ្នកអាចកែតម្រូវពន្លឺ ផ្ទាំងរូបភាព ការបង្វិលអេក្រង់ កំណត់ម៉ោងទូរសព្ទដេក និងទំហំពុម្ពអក្សរ ។ល។ (រូបភាព 4)

## ៨.៣.២ កំណត់សំឡេង

អ្នកអាចកំណត់សំឡេងរោទ៍ និងស្ថានភាពសំឡេងនៅក្នុងទូរសព្ទរបស់អ្នកនៅក្នុងការកំណត់សំឡេង ។ ចូលទៅ ការកំណត់ ហើយប៉ះលើពាក្យ **សំឡេង** ។




រូបភាព 4 : កំណត់ការបង្ហាញ




រូបភាព 5 : កំណត់សំឡេង

## ៨.៣.៣ កំណត់ពេលវេលា

ប្រសិនបើអ្នកត្រូវការកំណត់ពេលវេលានិងកាលបរិច្ឆេទនៅក្នុងទូរសព្ទរបស់អ្នក នៅពេលអ្នកចេញទៅបរទេស ឬក៏ពេលវេលាមានបញ្ហានោះ អ្នកចូលទៅ ការកំណត់ ដដែល បន្ទាប់មករំកិលចុះក្រោមហើយប៉ះលើពាក្យ **កាលបរិច្ឆេទ & ពេលវេលា** ។



# ៥ កម្មវិធីទំនាក់ទំនង

## ៥.១ បន្ថែមទំនាក់ទំនងក្នុង Android




នៅគ្រប់ទូរសព្ទនានា អ្នកអាចរក្សាទុកទំនាក់ទំនងនៅក្នុងនោះបានមានដូចជាលេខទូរសព្ទ អាសយដ្ឋានអ៊ីមែល និងកំណត់ចំណាំផ្សេងៗ។

អ្នកអាចបន្ថែមទំនាក់ទំនងថ្មីទៅក្នុងទូរសព្ទ Android របស់អ្នកតាមរយៈវិធីចំនួនពីរ។

### ៥.១.១ បន្ថែមផ្ទាល់ពីកន្លែងវាយលេខទូរសព្ទ

**វិធីទី១ ៖**

នៅខណៈពេលដែលអ្នកកំពុងវាយលេខទូរសព្ទ ហើយប៉ះនៅត្រង់ពាក្យ «បន្ថែមទៅទំនាក់ទំនង» ។




បន្ទាប់មកចុចនៅលើពាក្យ «បង្កើតទំនាក់ទំនងថ្មី» ដែលស្ថិតនៅផ្នែកខាងក្រោម។




អ្នកនឹងទៅដល់កន្លែងបញ្ចូលទិន្នន័យទំនាក់ទំនង។




ក្រោយពេលបំពេញព័ត៌មានរួចហើយ ប៉ះត្រង់ពាក្យ «រួចរាល់» ដើម្បីបញ្ចប់។

**វិធីទី២ ៖**

អ្នកអាចចូលបន្ថែមបានតាមរយៈកម្មវិធី «មនុស្ស» សម្រាប់គ្រប់គ្រងបញ្ជីទំនាក់ទំនងទាំងឡាយ។

1. ដាដំបូង ចូលទៅបញ្ជីកម្មវិធីទាំងអស់ ហើយប៉ះលើកម្មវិធី «មនុស្ស» ។
2. ប៉ះនៅត្រង់សញ្ញាបន្ថែម ដែលស្ថិតនៅកណ្តាលរបារផ្នែកខាងក្រោមអេក្រង់។



3. បន្ទាប់មកអ្នកនឹងទទួលបានបែបបទបំពេញព័ត៌មាន ដូចមានបង្ហាញនៅក្នុងវិធីទី១ដែរ។

## ៩.២ ការផ្ញើសារខ្លីៗ ឬអ៊ីមែល

នៅក្នុង Android 4.4+ អ្នកអាចផ្ញើអ៊ីមែលតាមរយៈកម្មវិធី Hangout ដែលនឹងនិយាយនៅពេលក្រោយ។ ចំណែកឯការផ្ញើសារខ្លីៗវិញ អ្នកអាចធ្វើតាមរយៈ Hangout ឬក៏កម្មវិធីជំនួយបន្ថែម (ដូចជា Sar Khmer, Contact+...) ។

### ៩.២.១ បើកការផ្ញើសារខ្លីៗនៅក្នុង Hangout

នៅក្នុង Android 4.4+ ត្រូវការកម្មវិធីបន្ថែមមួយដើម្បីផ្ញើសារ SMS ដូច្នេះអ្នកអាចប្រើកម្មវិធី Hangout របស់ Google បានដែរ ដោយអនុវត្តតាមជំហានខ្លីៗខាងក្រោមនេះ។

1. បើកកម្មវិធី Hangout នៅលើទូរសព្ទរបស់អ្នក។
2. ចូលទៅការកំណត់របស់ Hangout។
3. ប៉ះលើ SMS ។
4. ប៉ះលើ **បានបិទសារ SMS** ដើម្បីផ្លាស់ប្ដូរការកំណត់ទៅជា **បានបើកសារ SMS** ។

ក្រោយពេលដែលអ្នកបានបើកវារួចហើយ នោះសារ SMS នានារបស់អ្នកនឹងត្រូវបាននាំចូលទៅក្នុង Hangout ដោយស្វ័យប្រវត្តិ។

# ៦ ការដំឡើង និងលុបកម្មវិធីបន្ថែម

នៅក្នុងទូរសព្ទ Android អ្នកអាចដំឡើងកម្មវិធីបន្ថែមទៀតសម្រាប់ការប្រើប្រាស់និងកម្សាន្ត។ ក្នុងឆ្នាំ២០១៤នេះ មានកម្មវិធីប្រមាណ ១.២០០.០០០ កម្មវិធីដែលអ្នកអាចរកបាននៅទីនោះ។

## ៦.១ រកមើលនិងដំឡើងកម្មវិធី

1. ចូលទៅកាន់បញ្ជីកម្មវិធីទាំងអស់ បន្ទាប់មកប៉ះលើ Play Store ។
2. ប៉ះលើរូបកែវពង្រីក ដើម្បីរកមើលកម្មវិធី។ (រូបភាព 6)
3. ប៉ះលើសញ្ញាម៉ឺនុយដែលនៅខាងស្តាំ ឬក៏ប៉ះលើឈ្មោះកម្មវិធី ដើម្បីដំឡើង។ (រូបភាព 7 & 8)
4. រង់ចាំរហូតដល់ការទាញយកនិងដំឡើងបានបញ្ចប់ អ្នកនឹងឃើញកម្មវិធីនោះនៅក្នុងបញ្ជីកម្មវិធីទាំងអស់។




រូបភាព 6: ប៉ះនៅលើរូបកែពង្រីក ដើម្បីរកមើល។


khmer standard keyboard
Apps
1. Khmer Standard Keyboard
OPEN INSTITUTE
Install
2. Khmer Keyboard

រូបភាព 7


Apps
yboard
Khmer Sta
OPEN INSTITUTE
INSTALL
10:55
To
10:59
KH STD keyboard settings

រូបភាព 8

## ៦.២ ការលុបកម្មវិធី និងការធ្វើបច្ចុប្បន្នភាពកម្មវិធី

ក្រោយពេលដំឡើងហើយ ប៉ុន្តែអ្នកចង់លុបកម្មវិធីទាំងនោះវិញ ដូច្នេះសូមអនុវត្តតាមវិធីខាងក្រោម៖

1. ចូលទៅ «ការកំណត់» បន្ទាប់មកប៉ះលើ «កម្មវិធី» ។
2. រកមើលកម្មវិធីដែលអ្នកចង់លុប ហើយប៉ះលើឈ្មោះវា។
3. ប៉ះលើពាក្យ «លុប» គឺជាការស្រេច។



អ្នកក៏អាចលុប ឬ ធ្វើបច្ចុប្បន្នភាពបានតាមរយៈកម្មវិធី Play Store ដែរ ដោយចូលទៅទីនោះ ៖

1. អូសពីគែមអេក្រង់ខាងឆ្វេងមក ឬក៏ចុចលើម៉ឺនុយនៅជ្រុងលើខាងឆ្វេង ហើយប៉ះលើពាក្យ «My apps» ។ (រូបភាព 9)
2. រកមើលកម្មវិធីដែលអ្នកចង់លុប បន្ទាប់ប៉ះលើឈ្មោះកម្មវិធី ឬក៏ប៉ះលើម៉ឺនុយនៅខាងស្តាំឈ្មោះ ដើម្បីលុប ឬ ធ្វើបច្ចុប្បន្នភាពលើកម្មវិធីនោះ។ (រូបភាព 10)



រូបភាព 9



រូបភាព 10

# ៧ កម្មវិធីបណ្តាញសង្គម និង VoIP

ក្រៅអំពីរបៀបខ្លីៗនៃការប្រើប្រាស់ទូរសព្ទ Android ក៏មានកម្មវិធីផ្សេងៗទៀតដែលអ្នកគួរមាននៅក្នុងទូរសព្ទរបស់អ្នក។ ក្នុងនោះមានដូចជាបណ្តាញសង្គម និង VoIP ជាដើម។

បណ្តាញសង្គម គឺជាទីកន្លែងមួយផ្តល់មុខងារអន្តរកម្ម ដែលអាចឲ្យយើងទាក់ទងគ្នាទៅវិញទៅមកបានយ៉ាងងាយស្រួលនិងឆាប់រហ័ស។

VoIP (Voice Over Internet Protocol) គឺជាសេវាកម្មហៅទូរសព្ទតាមរយៈអ៊ីនធឺណិត។

ខាងក្រោមនេះ គឺជាបញ្ជីកម្មវិធីបណ្តាញសង្គម និង VoIP មួយចំនួន ដែលអ្នកអាចរកដំឡើងបានតាមរយៈ Play Store ។

## ៩. Facebook

Facebook ជាបណ្ដាញសង្គមដ៏ធំមួយនៅលើពិភពលោក។ វាមានភាពសម្បូរបែប និងមានមុខងារជាច្រើន ដែលយើងអាចប្រើបាន។



## ២. Google+

បណ្តាញសង្គមនេះ គឺជារបស់ក្រុមហ៊ុន Google Inc. ។ វាក៏មានមុខងារច្រើនមិនចាញ់ Facebook ប៉ុន្មានដែរ ។



## ៣. Twitter

បណ្ដាញសង្គមនេះអនុញ្ញាតឲ្យអ្នកផ្សាយព័ត៌មានខ្លីៗ បានរហ័ស និងអាចឲ្យអ្នកដទៃតាមដានយើង ឬក៏យើងតាមដានអ្នកដទៃវិញបានដែរ។



## ៤. Skype

Skype ជាប្រព័ន្ធ VoIP មួយដ៏ប្រសើរ ដែលអ្នកអាចហៅទូរសព្ទទៅអ្នកនៅក្នុង Skype ដោយមិនគិតប្រាក់ ឬក៏ទៅលេខទូរសព្ទផ្ទាល់នៅតាមប្រទេសនានាដោយគិតប្រាក់តាមតំបន់និមួយៗ។ ក្រៅពីនេះ អ្នកក៏អាចផ្ញើសារជជែកកម្សាន្ត និងហៅទូរសព្ទជាវីដេអូបានដែរ។



### ៥. WhatsApp

ជាកម្មវិធីផ្ញើសារបន្ទាន់ជាអក្សរ រូបភាព និងសំឡេងជាដើម។ វាមានភាពលឿនរហ័ស និងមានអ្នកប្រើជាច្រើនលាននាក់នៅលើពិភពលោក។



## ៦. Hangout

ដូចដែលបានលើកឡើងនៅខាងលើ អ្នកអាចប្រើ Google Hangout សម្រាប់ការផ្ញើសារ SMS, ឬក៏ជជែកកម្សាន្ត ដោយផ្ទាល់ជាមួយអ៊ីមែល Gmail របស់អ្នក។



## ៧. Viber

Viber ក៏ជាកម្មវិធីផ្ញើសារបន្ទាន់មួយដែរ ដែលមានភាពពេញនិយមនៅលើពិភពលោក។ វាមានភាពងាយស្រួល អាចទូរសព្ទបានដោយមិនគិតប្រាក់ (ប្រសិនបើមាន Viber ដូចគ្នា) ហើយអាចផ្ញើសារ ផ្ញើសំឡេង និងវីដេអូបានយ៉ាងងាយស្រួល។



## ៨. LINE

LINE ក៏កំពុងទទួលបានភាពនិយមនៅលើពិភពលោកដែរ។ វាត្រូវបានបង្កើតឡើងដោយក្រុមហ៊ុនជប៉ុន។ វាមានមុខងារផ្ញើសារបន្ទាន់, ហៅទូរសព្ទ, ផ្ញើវីដេអូ, និងមានហ្គេមកម្សាន្តថែមទៀតផង។

